កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

# គោលការណ៍ណែនាំ ស្ដីអំពី
# ការល្បាតនៅប្រព័ន្ធស្រះជម្រកត្រីសហគមន៍







គម្រោងអភិវឌ្ឍន៍វារីវប្បកម្ម និងសហគមន៍ស្រះជម្រកត្រីប្រកបដោយនិរន្តរភាព

ខែមករា ឆ្នាំ២០២៤

## បោះពុម្ព

ក្នុងនាមជាសហគ្រាសសហព័ន្ធ GIZ ជួយគាំទ្រដល់រដ្ឋាភិបាលអាល្លឺម៉ង់ក្នុងការសម្រេចគោលបំណងរបស់ខ្លួននៅក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។

**បោះពុម្ពដោយ៖**


ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (GIZ)

ការិយាល័យចុះបញ្ជី

Bonn និង Eschborn ប្រទេសអាល្លឺម៉ង់

Friedrich-Ebert-Allee 40

D-53113 Bonn, Germany

ទូរស័ព្ទ៖ +49 228 44 60-0

ទូរសារ៖ +49 228 44 60-17 66

Dag-Hammarskjöld-Weg 1-5

D-65760 Eschborn

ទូរស័ព្ទ៖ +49 61 96 79-0

ទូរសារ៖ +49 61 96 79-11 15

អ៊ីមែល៖ info@giz.de

www.giz.de


**អ្នកនិពន្ធ៖**


អ៊ូ ភិចហុង  ស៊ាន វិចិត្រ  ស៊ុន វឌ្ឍនៈ ឈី សាវីរ៉  លឹម ង៉ែត  ម៉ម សុវណ្ណារី  ភិន ភារម្យ

អេង គឹមឡេង  សាម៉ន់ ចាន់ណា


**សហការរៀបចំ និងត្រួតពិនិត្យបច្ចេកទេសដោយ៖**


នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម (DAD) នៃរដ្ឋបាលជលផល

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ធំ និង ខេត្តបាត់ដំបង

ខណ្ឌរដ្ឋបាលជលផល ខេត្តកែប កំពង់ឆ្នាំង កំពង់ចាម កំពង់ធំ កំពង់ស្ពឺ កំពត កោះកុង ត្បូងឃ្មុំ តាកែវ ប៉ៃលិន បន្ទាយមានជ័យ បាត់ដំបង ព្រះវិហារ ព្រៃវែង មណ្ឌលគិរី រតនគិរី សៀមរាប និង ខេត្តឧត្តរមានជ័យ

ក្រុមហ៊ុនប្រឹក្សាយោបល់ GFA

# អារម្ភកថា

វាលស្រែលិចទឹកនៅព្រះរាជាណាចក្រកម្ពុជា ផ្តល់សក្តានុពលយ៉ាងសំខាន់ចំពោះការពងកូន និងរីកធំធាត់របស់ត្រី និងវារីសត្វគ្រប់ប្រភេទ ដែលបានផ្តល់ជាអាហារសម្រាប់ប្រជាពលរដ្ឋកម្ពុជារាប់លាននាក់បានអាស្រ័យផលពីធនធានធម្មជាតិមួយនេះ។ ជាទូទៅ វាលស្រែលិចទឹកនៅរដូវវស្សាមានរយៈពេលប្រមាណ៦ខែ ផ្តល់ជាទីកន្លែងសម្រាប់ត្រី និងវារីសត្វបង្កកំណើត និងរីកធំធាត់។ វាលស្រែលិចទឹកនេះ តភ្ជាប់នឹងស្រះជម្រកត្រីសហគមន៍ ដោយផ្លូវទឹក(រួមមានផ្លូវត្រីចេញ ចូល ប្រឡាយ អូរ ស្ទឹង ជាដើម) បង្កើតបានជាប្រព័ន្ធធនធានជលផលតាមវាលស្រែ ដែលផ្តល់ជាទីកន្លែងនេសាទដល់ប្រជាពលរដ្ឋទូទៅ។

យោងលើសារៈប្រយោជន៍នៃធនធានធម្មជាតិនេះ នៅឆ្នាំ២០០៧ ប្រមុខរាជរដ្ឋាភិបាល បានដាក់ចេញនូវអនុសាសន៍បង្កើតស្រះជម្រកត្រីសហគមន៍មួយ ក្នុងមួយឃុំ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ការគ្រប់គ្រងប្រព័ន្ធនេះបានល្អ ជួយការពារ និងអភិរក្សធនធានជលផលប្រកបដោយនិរន្តរភាព។

ដោយពិនិត្យឃើញថា សកម្មភាពល្បាតក្នុងប្រព័ន្ធស្រះជម្រកត្រីសហគមន៍ ជាចំណែកសកម្មភាពមួយសំខាន់ក្នុងការជួយបង្កើនផលស្តុកត្រីធម្មជាតិ និងការពារពូជត្រី ដើម្បីធានានិរន្តរភាពនៃធនធានជលផល រដ្ឋបាលជលផលសហការជាមួយ អង្គការWorldFish និងគម្រោង GIZ-SAFR បានរៀបចំចងក្រង **គោលការណ៍ណែនាំស្តីពីការល្បាតនៅប្រព័ន្ធស្រះជម្រកត្រីសហគមន៍** សម្រាប់ជាឯកសារជំនួយបច្ចេកទេសក្នុងការគ្រប់គ្រងប្រព័ន្ធស្រះជម្រកត្រី។ ឯកសារនេះបានបរិយាយពីកត្តាគំរាមកំហែងចំពោះស្រះជម្រកត្រី គោលបំណងនៃការល្បាត ការទទួលខុសត្រូវរបស់ក្រុមល្បាត ទីតាំង និងពេលវេលាល្បាត ជំហាននៃការល្បាតស្រះជម្រកត្រី(ការយល់ដឹងពីច្បាប់ ស្តីពីជលផល និងលក្ខន្តិករបស់សហគមន៍ វិធានការអំឡុងពេលល្បាត) ការត្រួតពិនិត្យ និងវាយតម្លៃ។

ខ្ញុំសង្ឃឹមថា គោលការណ៍ណែនាំនេះ ឆ្លើយតបទៅនឹងតម្រូវការសហគមន៍ស្រះជម្រកត្រីសម្រាប់អនុវត្តនៅសហគមន៍របស់ខ្លួន និងជាឯកសារក្នុងការរៀបចំគោលនយោបាយ និងផែនការសកម្មភាព សំដៅការពារ និងគ្រប់គ្រងធនធានជលផលតាមវាលស្រែ ឱ្យមាននិរន្តរភាព។

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**ពុំ សុថា**

giz

# តារាងមាតិកា


១. សេចក្តីផ្តើម ........................................................................................................ 1

១.១ កត្តាគំរាមកំហែងចំពោះស្រះជម្រកត្រី ......................................................................... 1

១.២ អត្ថប្រយោជន៍នៃគោលការណ៍ណែនាំ......................................................................... 1

១.៣ វិធីសាស្រ្តក្នុងការរៀបចំ .............................................................................................. 2

២. គោលបំណងល្បាត សមាសភាព និងតួនាទីក្រុមល្បាត........................................................ 3

២.១ គោលបំណងនៃការល្បាត ............................................................................................ 3

២.២ ការចងក្រងសមាសភាពក្រុមល្បាត............................................................................... 3

២.៣ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមល្បាត ................................................................ 3

៣. ទីតាំង និងពេលវេលា ល្បាត ..................................................................................... 4

៣.១ ផ្នែកស្រះជម្រកត្រី.................................................................................................... 4

៣.២ ផ្នែកផ្លូវត្រីចរាចរណ៍.................................................................................................. 4

៣.៣ ផ្នែកវាលស្រែលិចទឹក៖ ............................................................................................. 4

៤. ជំហានក្នុងការល្បាតស្រះជម្រកត្រី.................................................................................. 6

ជំហានទី១៖ ការយល់ដឹងច្បាប់ ស្តីពីជលផល និងលក្ខន្តិករបស់សហគមន៍................................. 6

ជំហានទី២៖ សម្ភារៈល្បាត ............................................................................................. 7

ជំហានទី៣៖ វិធានការអំឡុងពេលល្បាត .............................................................................. 7

ជំហានទី៤៖ ការត្រួតពិនិត្យ និងវាយតម្លៃ............................................................................. 8

ឧបសម្ព័ន្ធ.................................................................................................................. 9

ឯកសារយោង...............................................................................................................14

# ១. សេចក្តីផ្តើម

ស្រះជម្រកត្រីសហគមន៍ត្រូវបានបង្កើតឡើងក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៨ ដែលបច្ចុប្បន្ន មានចំនួនប្រមាណ៩១៥ (ទិន្នន័យជលផលឆ្នាំ២០២១)។ តាមរយៈការស្រាវជ្រាវរបស់អង្គការWorldFish ការគ្រប់គ្រងស្រះជម្រកត្រីបានល្អ បានបង្កើនផលចាប់ត្រីប្រមាណ ៧១% ដល់គ្រួសារក្រីក្រ ដែលពឹងផ្អែកលើការនេសាទត្រីតាមវាលស្រែ។ ការគ្រប់គ្រងស្រះជម្រកត្រីសហគមន៍ គឺរួមបញ្ចូលសកម្មភាពជាច្រើនមានដូចជា ការជីកស្តារស្រះ និងប្រឡាយ ធ្វើផ្លូវត្រីចេញ ចូល ការដាក់ជម្រក ។ល។ ក្នុងនោះ ល្បាតគឺជាសកម្មភាពមួយសំខាន់។

ការល្បាតទៀងទាត់ជាប្រចាំ នាំមកនូវការថែរក្សាត្រីមេពូជនៅក្នុងស្រះជម្រកត្រី[1]នៅរដូវប្រាំង ដើម្បីបន្តការបង្កកំណើត និងពងកូននៅតាមប្រព័ន្ធស្រះជម្រកត្រី នៅរដូវវស្សានាឆ្នាំបន្ទាប់។

## ១.១ កត្តាគំរាមកំហែងចំពោះស្រះជម្រកត្រី

ត្រីនៅតាមប្រព័ន្ធស្រះជម្រកត្រីជាប្រភពអាហារដ៏សំខាន់មួយ និងផ្តល់ប្រាក់ចំណូលដល់ប្រជាជនរាប់លាននាក់ទូទាំងប្រទេសកម្ពុជា។ បច្ចុប្បន្នកំពុងប្រឈមនូវកត្តាជាច្រើន មានដូចជា កំណើនប្រជាពលរដ្ឋ បម្រែបម្រួលអាកាសធាតុ បាត់បង់ទីជម្រក បទល្មើសនេសាទ ។ល។ ដែលបញ្ហាប្រឈមនេះ បាននឹងកំពុងគំរាមកំហែងទាំងបរិមាណ និងគុណភាពត្រីធម្មជាតិ។

នាដើមរដូវវស្សា នៅពេលភ្លៀងធ្លាក់ច្រើន ស្រះជម្រកត្រីតភ្ជាប់ឡើងវិញទៅនឹងវាលស្រែ ត្រីចរាចរចេញពីស្រះទៅវាលស្រែ តាមផ្លូវទឹកត្រីចេញ ចូល ឬប្រឡាយ ដើម្បីពងកូន លូតលាស់ និងធំធាត់នៅតាមវាលស្រែ។ នាចុងរដូវវស្សា ទឹកនៅតាមវាលស្រែចាប់ផ្តើមស្រក ត្រីចាប់ផ្តើមវិលត្រឡប់មកស្រះជម្រកវិញ។ បទល្មើសនេសាទតែងកើតមានឡើងនៅតាមផ្លូវត្រីចេញ ចូល មានដូចជា ការដាក់ឧបករណ៍ដើម្បីរាំងស្ទាក់ចាប់ ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ផ្សេងៗ។ អំឡុងពេលរដូវប្រាំងដែលមានរយៈពេល៦ខែ ត្រីជ្រកកោនក្នុងស្រះជម្រក ក្នុងពេលនោះអាចកើតមានបទល្មើសនេសាទ។

## ១.២ អត្ថប្រយោជន៍នៃគោលការណ៍ណែនាំ

គោលការណ៍ណែនាំស្តីអំពីការល្បាតនៅប្រព័ន្ធស្រះជម្រកត្រីសហគមន៍ បានផ្តួចផ្តើមរៀបចំចងក្រងដើម្បី៖

[1] ជាកន្លែងត្រីជ្រកកោនក្នុងរដូវប្រាំង នៅពេលផ្លូវទឹក និងវាលស្រែត្រូវបានកាត់ផ្តាច់ដោយការរីងរាក់។

- ជាជំនួយបច្ចេកទេស និងចំណេះដឹងដល់ក្រុមល្បាតរបស់សហគមន៍ស្រះជម្រកត្រី ក្នុងការការពារពូជត្រី ទប់ស្កាត់សកម្មភាពនេសាទខុសច្បាប់
- ឆ្លើយតបទៅនឹងតម្រូវការសកម្មភាពល្បាត ដែលសកម្មភាពនេះបាននឹងកំពុងធ្វើដោយគណៈកម្មការសហគមន៍ស្រះជម្រកត្រី អាជ្ញាធរដែនដី និងខណ្ឌរដ្ឋបាលជលផល
- ជាប្រភពឯកសារយោង សម្រាប់ជួយឱ្យសហគមន៍ស្រះជម្រកត្រីទូទាំងប្រទេសកម្ពុជាប្រើប្រាស់ និងអនុវត្តសកម្មភាពល្បាតប្រកបដោយប្រសិទ្ធភាព
- រួមចំណែកក្នុងការផ្តល់ប្រភពព័ត៌មានក្នុងការរៀបចំគោលនយោបាយ និងធ្វើផែនការសកម្មភាពពាក់ព័ន្ធ។

## ១.៣ វិធីសាស្ត្រក្នុងការរៀបចំ

គោលការណ៍ណែនាំនេះរៀបចំឡើងតាមវិធីសាស្ត្រដូចខាងក្រោម៖

- ស្រាវជ្រាវឯកសារដែលពាក់ព័ន្ធការងារល្បាត
- សិក្ខាសាលាពិគ្រោះយោបល់ចំនួនពីរលើក[2] ប្រមូលបទពិសោធន៍ដែលបានអនុវត្តជាក់ស្តែងកន្លងមកដោយសហគមន៍មូលដ្ឋាន មន្ត្រីជំនាញរដ្ឋបាលជលផល អ្នកជំនាញរបស់ស្ថាប័នឯកជន និងអង្គការមិនមែនរដ្ឋាភិបាល
- ប្រជុំពិភាក្សាលើគោលការណ៍ណែនាំ ដែលបានពង្រាងជាមួយមន្ត្រីរដ្ឋបាលជលផលថ្នាក់ជាតិអំឡុងខែមករា និងខែកុម្ភៈ ឆ្នាំ២០២៣
- ផ្អែកលើបទពិសោធន៍ជាក់ស្តែងក្នុងការល្បាតស្រះជម្រកត្រី ក្នុងគម្រោងអភិវឌ្ឍន៍វារីវប្បកម្ម និងសហគមន៍ស្រះជម្រកត្រីប្រកបដោយនិរន្តរភាព ផ្នែកសហគមន៍ស្រះជម្រកត្រី (គម្រោងសេហ្វ ស៊ី អេហ្វ អ) និងគម្រោងធនធានជលផលតាមវាលស្រែដំណាក់កាលទី២។

[2] សិក្ខាសាលាលើកទី១ធ្វើឡើងនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ នៅខេត្តកំពង់ធំ សិក្ខាសាលាលើកទី២ធ្វើឡើងនៅទី៣០ ខែឧសភា ឆ្នាំ២០២៣ នៅខេត្តបាត់ដំបង មានការចូលរួមពីប្រធានមន្ទីរកសិកម្ម មន្ត្រីរដ្ឋបាលជលផលថ្នាក់ជាតិ និងក្រោមជាតិ អ្នកជំនាញបច្ចេកទេសវារីវប្បកម្មរបស់ស្ថាប័នឯកជន ប្រធានឬតំណាងសហគមន៍ស្រះជម្រកត្រី និងក្រុមប្រឹក្សាឃុំ។

## ២. គោលបំណងល្បាត សមាសភាព និងតួនាទីក្រុមល្បាត

### ២.១ គោលបំណងនៃការល្បាត

ជាទូទៅគោលបំណងសំខាន់នៃការល្បាត គឺដើម្បីការពារ ថែរក្សា អភិរក្សពូជត្រី និងវារីសត្វ ដើម្បីបន្តនូវផលិតកម្មត្រី និងសន្តិសុខស្បៀងក្នុងពេលបច្ចុប្បន្ន និងអនាគត។

សកម្មភាពល្បាតក្នុងប្រព័ន្ធស្រះជម្រកត្រីមានគោលបំណងដូចខាងក្រោម៖

- ទប់ស្កាត់ការនេសាទខុសច្បាប់គ្រប់ប្រភេទនៅក្នុងប្រព័ន្ធស្រះជម្រកត្រី
- ទប់ស្កាត់ការនេសាទគ្រប់ប្រភេទនៅកន្លែងអភិរក្សនៃប្រព័ន្ធស្រះជម្រកត្រី
- បញ្ជ្រាបការផ្សព្វផ្សាយអំពី អត្ថប្រយោជន៍ កិច្ចការពារ និងថែរក្សាត្រីនៅសហគមន៍ស្រះជម្រកត្រី
- បន្ត និងពង្រឹងកិច្ចការគ្រប់គ្រងស្រះជម្រកត្រីសហគមន៍ និងធនធានជលផលតាមវាលស្រែប្រកបដោយនិរន្តរភាព។

### ២.២ ការចងក្រងសមាសភាពក្រុមល្បាត

ក្នុងរចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងសហគមន៍ស្រះជម្រកត្រី មានប្រធានក្រុមល្បាតដែលបានបង្កើតឡើងតាមរយៈការបោះឆ្នោត។ ចំណែកសមាជិកក្រុមល្បាតជ្រើសតាំងដោយមេឃុំ និងអាជ្ញាធរដែនដីពាក់ព័ន្ធ មានសមាសភាពដូចខាងក្រោម៖

- គណៈកម្មការសហគមន៍
- អាជ្ញាធរដែនដី (មេភូមិ អនុភូមិ សមាជិកភូមិ)
- ប្រជាការពារ
- ប្រជាពលរដ្ឋ ឬសមាជិកសហគមន៍

ក្រុមល្បាតអាចមានពី២ទៅ៧ក្រុម ដែលសមាសភាពក្នុង១ក្រុម មានសមាជិក ២ទៅ៥នាក់ អាស្រ័យលើទំហំ ចំងាយ ទីតាំង ស្រះជម្រកត្រី និងតំបន់ការពារ ។ ក្រុមនេះត្រូវទទួលស្គាល់ជាផ្លូវការ និងអនុញ្ញាតឱ្យល្បាតដោយមេឃុំ ។

### ២.៣ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមល្បាត

តួនាទី និងការទទួលខុសត្រូវរបស់ក្រុមល្បាតត្រូវបានពិភាក្សា និងឯកភាពគ្នាក្នុងពេលដំណើរការរៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មការ និងបានចែងក្នុងលក្ខន្តិករបស់សហគមន៍។

តួនាទី និងការទទួលខុសត្រូវសំខាន់ៗរបស់ក្រុមល្បាតរួមមាន៖

- ទប់ស្កាត់ការដាក់ឧបករណ៍នេសាទគ្រប់ប្រភេទនៅក្នុងដែនអភិរក្សស្រះជម្រកត្រី នៅតាមផ្លូវត្រីចេញ ចូលដែលភ្ជាប់ពីស្រះជម្រកត្រីទៅវាលស្រែ
- រឹបអូសឧបករណ៍ដែលរកឃើញនៅផ្លូវត្រីចេញ ចូល ក្នុងស្រះជម្រកត្រី នៅតំបន់ការពារ
- រាយការណ៍ករណីបទល្មើសជាបន្ទាន់ ថតរូប និងប្រមូលវត្ថុតាង ប្រគល់ទៅអាជ្ញាធរដែនដី កងកំលាំងមានសមត្ថកិច្ច និងមន្រ្តីជលផល ដែលនៅជិតបំផុត ដើម្បីចាត់វិធានការទៅតាមច្បាប់។

## ៣. ទីតាំង និងពេលវេលា ល្បាត

សកម្មភាពល្បាត អនុលោមទៅតាមលក្ខន្តិក រួមទាំងបទបញ្ញត្តិសហគមន៍ ស្តីអំពីប្រភេទឧបករណ៍នេសាទ កន្លែងអភិរក្ស និងតំបន់ការពារ ដែលខុសៗគ្នាទៅតាមសហគមន៍នីមួយៗ ។ សកម្មភាពល្បាតអាចអនុវត្តជារួម ផ្តោតលើទីតាំង ឬផ្នែកនីមួយៗនៃប្រព័ន្ធស្រះជម្រកត្រីតាមរដូវកាល និងពេលវេលាដូចខាងក្រោម៖

**៣.១ ផ្នែកស្រះជម្រកត្រី៖** នៅរដូវប្រាំង ស្រះជម្រកត្រីជាកន្លែងដែលត្រីអាចរស់នៅបាន ហេតុនេះវាបានទាក់ទាញអ្នកនេសាទមកនេសាទនៅទីនេះ ទោះបីពួកគាត់ដឹង ឬមិនដឹងថា ជាកន្លែងអភិរក្សត្រូវបានហាមឃាត់ដោយច្បាប់ក៏ដោយ។

**៣.២ ផ្នែកផ្លូវត្រីចរាចរណ៍៖** ផ្លូវត្រីចរាចរណ៍ រួមមានប្រឡាយ អូរ ព្រែក និងទម្រង់ផ្លូវទឹកផ្សេងៗទៀត ដែលតភ្ជាប់ស្រះជម្រកត្រីទៅនឹងប្រព័ន្ធអេកូឡូស៊ីវាលស្រែតាមរយៈផ្លូវត្រីចេញចូល។ ផ្លូវត្រីចរាចរណ៍នេះ ដើរតួនាទីយ៉ាងសកម្ម ក្នុងការបន្លាស់ទីរបស់ត្រីពីស្រះជម្រកត្រីទៅវាលស្រែ ដើម្បីពងកូននៅរដូវវស្សា និងត្រឡប់មកស្រះជម្រកត្រីវិញដើម្បីជ្រកកោននៅរដូវប្រាំង។ ជាញឹកញាប់ សកម្មភាពនេសាទខុសច្បាប់ត្រូវបានគេរកឃើញនៅតាមផ្លូវត្រីចរាចរណ៍ជាពិសេសនៅតំបន់ជិតស្រះជម្រកត្រី។ ការល្បាតនៅផ្នែកនេះសំខាន់ណាស់ ដើម្បីត្រួតពិនិត្យការរាំងខ្ទប់ចរាចរត្រី ជាពិសេសនៅដើមរដូវវស្សា ចាប់ពីខែឧសភាដល់កក្កដា និងចុងរដូវវស្សាចាប់ពីខែវិច្ឆិកាដល់ខែធ្នូ។ ការល្បាតអំឡុងពេលនេះបានទៀងទាត់ ជួយសម្រួលដល់ត្រីឱ្យទៅពងកូន និងត្រឡប់ចូលស្រះវិញដោយសុវត្ថិភាព។

**៣.៣ ផ្នែកវាលស្រែលិចទឹក៖** ជាកន្លែងដែលត្រី បង្កកំណើត ផ្តល់ចំណីធម្មជាតិសម្បូណ៌បែប ពងកូន និងធំធាត់។ ផ្នែកនេះជាទីកន្លែងដែលប្រជាពលរដ្ឋទូទៅនេសាទត្រី សម្រាប់ធ្វើម្ហូបប្រចាំថ្ងៃ។ សហគមន៍ភាគច្រើនកំណត់ទុកតំបន់ការពារក្នុងទំហំផ្សេងៗគ្នា ដែលមានចែងក្នុងលក្ខន្តិក។ ក្រៅពីតំបន់ការពារ សកម្មភាពល្បាតអាចអនុវត្តនៅវាលស្រែ ដែលមិនកំណត់រយៈ

ចំងាយ តែអាចផ្តោតលើសិទ្ធិ ដែលប្រជាពលរដ្ឋមាន គឺអាចរាយការណ៍ នៅពេលឃើញមានបទល្មើសទាក់ទងនឹងការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ និងសកម្មភាពខុសច្បាប់ដូចជា កាប់ប្រឡាយបង្ហូរទឹកយកត្រី ដាក់ឧបករណ៍នេសាទខុសច្បាប់(ឆក់ដោយប្រើគ្រឿងអេឡិចត្រូនិច)។

ដោយសារផ្នែកនេះមានផ្ទៃធំល្វឹងល្វើយ ធៀបចំនួនក្រុមល្បាតដែលមានកំណត់ គឺពិបាកក្នុងការល្បាត និងគ្រប់គ្រង។ ក្នុងករណីសហគមន៍មានបំណងល្បាតនៅតាមវាលស្រែ ក្រៅពីតំបន់ការពារ គេគួរតែពិភាក្សា និងឯកភាពរវាងមន្ត្រីជំនាញជលផល មេឃុំ ឬក្រុមប្រឹក្សាឃុំ ជាពិសេសកំណត់ចំងាយ ពេលវេលា ភាពញឹកញាប់ក្នុងការល្បាត និងផ្តោតលើការប្រើប្រាស់ឧបករណ៍នេសាទ។

**ចំណុចបន្ថែមទី១៖** ទំនាក់ទំនងរវាងភាពញឹកញាប់នៃល្បាត សកម្មភាពអន្តរាគមន៍ និងទីតាំងស្រះជម្រកត្រី

- សកម្មភាពអន្តរាគមន៍ ដូចជាការជីកស្តារជម្រៅស្រះ ការដាក់ជម្រកក្នុងស្រះជម្រកត្រី ជួយកាត់បន្ថយសកម្មភាពល្បាត។
- ទីតាំងរបស់ស្រះជម្រកត្រី ផ្លូវត្រីចេញ ចូល តំបន់ការពារ ស្ថិតនៅក្នុងភូមិ ឬក្បែរភូមិ ក៏ជួយរួមចំណែកក្នុងការកាត់បន្ថយសកម្មភាពល្បាតផងដែរ។
- ស្រះជម្រកត្រីរីងរាក់ និងទីតាំងផ្នែកទាំងបីនេះ (ស្រះជម្រកត្រី ផ្លូវត្រីចរាចរ វាលស្រែ) នៅឆ្ងាយពីភូមិ កិច្ចការល្បាតគួរតែអនុវត្តញឹកញាប់។

**ចំណុចបន្ថែមទី២៖** ក្រុមល្បាតត្រូវសិក្សាស្វែងយល់អំពី ទម្លាប់ និងសកម្មភាពនេសាទខុសច្បាប់របស់ជនល្មើស ដូចជាម៉ោង ពេល និងទីកន្លែងដែលជនល្មើសទៅនេសាទខុសច្បាប់ជារឿយៗ។
**ចំណុចបន្ថែមទី៣៖** ករណីសិក្សា អំពីការអនុវត្តជាក់ស្តែងរបស់ក្រុមល្បាតនៅសហគមន៍ស្រះជម្រកត្រីក្អែកងូត នៅភូមិកំពង់ឈើទាល ឃុំតាំងក្រសៅ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។

- នៅរដូវប្រាំង ចន្លោះខែវិច្ឆិកា ដល់ខែឧសភា៖ ក្រុមល្បាតប្រើប្រាស់ម៉ូតូ ដើម្បីល្បាតក្នុងរយៈពេលប្រមាណ៦ម៉ោង(មិនជាប់គ្នា) ក្នុងមួយថ្ងៃ។
  - ពេលព្រឹកចាប់ពីម៉ោង៥ដល់ម៉ោង៧ ពេលរសៀលចាប់ពីម៉ោង១ដល់ម៉ោង៣។
  - ពេលល្ងាច ចាប់ពីម៉ោង៥ ដល់ម៉ោង៧យប់។
- ក្រៅពីពេលវេលាល្បាតជាទៀងទាត់ ដែលបានកំណត់ជាមួយសមាជិកផ្សេងទៀត ក្រុមល្បាតបានឆ្លៀតចុះត្រួតពិនិត្យក្រៅពីម៉ោងដែលបានកំណត់។
- នៅរដូវវស្សា ចាប់ពីខែមិថុនាដល់ខែតុលា ក្រុមល្បាតប្រើប្រាស់ទូកដើម្បីល្បាតទាំងពេលថ្ងៃ និងពេលយប់។

**ចំណុចបន្ថែមទី៤៖** ទំនាក់ទំនងរវាងធាតុអាកាស និងការនេសាទខុសច្បាប់ -ធាតុអាកាសក៏មានទំនាក់ទំនងជាមួយការនេសាទខុសច្បាប់ ហេតុនេះក្រុមល្បាតគួរតែបន្ថែមចំនួនសកម្មភាពល្បាតទៅតាមពេលវេលាដូចខាងក្រោម៖

- នៅដើមរដូវវស្សា(ចាប់ពីខែឧសភាដល់ខែកក្កដា) នៅពេលមានភ្លៀងធ្លាក់ច្រើន ជនប្រព្រឹត្តបទល្មើសនេសាទខុសច្បាប់ក៏ចាប់ផ្តើមប្រតិបត្តិការ។
- ចុងរដូវវស្សា(ចាប់ពីខែវិច្ឆិកាដល់ខែធ្នូ) ជារដូវកាលត្រជាក់ខ្យល់ធ្លាក់ពីជើង ត្រីវិលត្រលប់មកពីវាលស្រែចូលស្រះជម្រកត្រីវិញ អ្នកនេសាទខ្លះស្ទាក់ចាប់ត្រីដោយប្រើឧបករណ៍ខុសច្បាប់ (ឆក់ ស្បៃមុង ដាក់ព្រួលរាំងស្ទះចរាចរណ៍ត្រី)។

## ៤. ជំហានក្នុងការល្បាតស្រះជម្រកត្រី

### ជំហានទី១៖ ការយល់ដឹងច្បាប់ ស្តីពីជលផល និងលក្ខន្តិកៈរបស់សហគមន៍

សមាជិកក្រុមល្បាតទាំងអស់ ត្រូវតែទទួលការបណ្តុះបណ្តាលលើប្រធានបទជាច្រើន ដើម្បីអនុវត្តសកម្មភាពល្បាតបានត្រឹមត្រូវ ជោគជ័យ ប្រកបដោយសុវត្ថិភាព។

**ប្រធានបទបណ្តុះបណ្តាលរួមមាន៖**

- ច្បាប់ស្តីពីជលផល មាត្រាពាក់ព័ន្ធនឹងកិច្ចការពារ អភិរក្ស ឧបករណ៍នេសាទ ទោសទណ្ឌ
- លក្ខន្តិកៈរបស់សហគមន៍ស្រះជម្រកត្រី (ទីកន្លែងអភិរក្ស ដែនការពារ ឧបករណ៍នេសាទ និងដំណោះស្រាយ)
- តួនាទី និងការទទួលខុសត្រូវក្នុងសកម្មភាពល្បាត
- ប្រព័ន្ធស្រះជម្រកត្រីសហគមន៍ និងមុខងារ
- របៀបប្រើប្រាស់ឧបករណ៍ល្បាតដូចជា វិទ្យុទាក់ទង កាមេរ៉ាល្បាត ជាដើម
- យន្តការដោះស្រាយបទល្មើស
- ការរៀបចំផែនការសកម្មភាពល្បាតបានច្បាស់លាស់
- ការរៀបចំឯកសារកត់ត្រាដើម្បីត្រួតពិនិត្យ និងតាមដាន (សកម្មភាពល្បាត សកម្មភាពជនល្មើស ឧបករណ៍ខុសច្បាប់ នៅក្នុងពេលល្បាត និងរាយការណ៍)។
- ការវាយតម្លៃអំពីស្ថានភាពមុនពេលល្បាត៖ ឧទាហរណ៍ មុនពេលចាប់ផ្តើមសកម្មភាពក្រុមល្បាតវាយតម្លៃអំពី ស្ថានភាពបទល្មើសនៃផ្នែកទាំងបីនៃប្រព័ន្ធស្រះជម្រកត្រី ទីតាំង និងពេលវេលាដែលសកម្មភាពនេសាទខុសច្បាប់កើតឡើងជាញឹកញាប់ បទល្មើសជាក់ស្តែង ប្រភេទឧបករណ៍ខុសច្បាប់ដែលរកឃើញដោយសហគមន៍ ប្រៀបធៀបសកម្មភាព

ខុសច្បាប់(កើនឬថយ) សិក្សាស្វែងរកមូលហេតុ និងដំណោះស្រាយធៀបចំនួនករណីដែលត្រូវបានរាយការណ៍ ដំណោះស្រាយដោយអាជ្ញាធរដែនដី និងសមត្ថកិច្ចជំនាញ។

## ជំហានទី២៖ សម្ភារៈល្បាត

ដើម្បីល្បាតជោគជ័យ ក្រុមល្បាតគួរត្រៀមសម្ភារៈ និងឯកសារមួយចំនួនដូចខាងក្រោម៖ វិទ្យុទាក់ទង ទូរស័ព្ទ លេខទូរស័ព្ទរបស់អាជ្ញាធរពាក់ព័ន្ធ អាវភ្លៀង (នៅរដូវវស្សា) ពិល ម៉ូតូ ទូក ឬ កាណូត មុង អង្រឹង ឯកសណ្ឋានល្បាត ស្បែកជើងកវែង កាមេរ៉ាដើរដោយពន្លឺព្រះអាទិត្យ រោងយាម សម្ភារៈសង្គ្រោះបន្ទាន់។ ម៉្យាងទៀត ក្រុមល្បាតក៏ត្រូវចេះប្រើប្រាស់ឧបករណ៍ល្បាតទាំងនេះ ដូចជាការតភ្ជាប់វិទ្យុទាក់ទងជាមួយអាជ្ញាធរដែនដី (ឃុំ ប៉ូលីស) ការតភ្ជាប់ និងប្រើប្រាស់កាមេរ៉ាដើរដោយពន្លឺព្រះអាទិត្យ ។ ក្នុងករណីដែលសហគមន៍មានលទ្ធភាពបំពាក់កាមេរ៉ាដើរដោយពន្លឺព្រះអាទិត្យ គួរតែប្រើប្រាស់ឧបករណ៍នេះ ព្រោះវាជួយយ៉ាងខ្លាំងដល់ការល្បាត ដូចជាសន្សំពេលវេលាដល់ក្រុមល្បាត អាចរកឃើញជនល្មើសដោយមានភស្តុតាង។

## ជំហានទី៣៖ វិធានការអំឡុងពេលល្បាត

នៅពេលដែលក្រុមល្បាតឃើញ ឬជួបប្រទះប្រភេទបទល្មើសណាមួយ ដូចជា ឧបករណ៍ខុសច្បាប់ សកម្មភាពនេសាទខុសច្បាប់ កើតឡើងនៅតាមប្រព័ន្ធស្រះជម្រកត្រី៖

- ក្រុមល្បាតអាចថតរូបជនប្រព្រឹត្តបទល្មើសព្រមទាំងវត្ថុតាង រាយការណ៍បញ្ជូនមកអាជ្ញាធរដែនដី និងមន្ត្រីជំនាញ ដែលនៅជិតបំផុតដើម្បីដោះស្រាយ។
- ក្រុមល្បាតណែនាំ និងអប់រំជនល្មើស ដោយមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរ
- ករណីដែលជនល្មើសនោះនៅតែបន្តសកម្មភាពផ្ទុយពីលក្ខន្តិក និងបទប្បញ្ញត្តិរបស់សហគមន៍ ក្រុមល្បាតរាយការណ៍ជាបន្ទាន់ជូនទៅអាជ្ញាធរមូលដ្ឋាន ស្ថាប័ន និងសមត្ថកិច្ចជំនាញជលផលដើម្បីដោះស្រាយតាមច្បាប់។
- ការផាកពិន័យ ឬការដាក់ទណ្ឌកម្មចំពោះជនល្មើស ត្រូវអនុលោមតាមច្បាប់ស្តីពីជលផល និងតារាងសងការខូចខាតលើបទល្មើសជលផលផ្សេងៗ។ ទោសប្បញ្ញត្តិ និងកម្រិតការផាកពិន័យចំពោះសកម្មភាពនេសាទខុសច្បាប់ មានចែងក្នុងលក្ខន្តិករបស់សហគមន៍នីមួយៗ និងមានកម្រិតខុសៗគ្នាទៅតាមសហគមន៍។
- រាល់សំណងខូចខាតទាំងអស់ត្រូវមានវិក័យប័ត្រ និងកំណត់ហេតុត្រឹមត្រូវដែលទទួលដឹងឮពីអាជ្ញាធរភូមិ ឃុំ និងប៉ុស្តិ៍រដ្ឋបាល ឬជំនាញជលផល ។

ព័ត៌មានលំអិត សូមមើលបន្ថែមលើតារាងឧបសម្ព័ន្ធ១ ស្តីអំពីវិធានការជំនួយដល់ក្រុមល្បាត ដែលបានបរិយាយប្រភេទបទល្មើស ប្រភេទឧបករណ៍ និងដំណោះស្រាយ។

## ជំហានទី៤៖ ការត្រួតពិនិត្យ និងវាយតម្លៃ

ប្រធានសហគមន៍ ឬមេឃុំពិនិត្យជាប្រចាំអំពីសកម្មភាពល្បាត ដើម្បីវាយតម្លៃពីប្រសិទ្ធភាពនៃសកម្មភាពល្បាត។ ដំណើរការពិនិត្យរួមមាន៖

- ពិនិត្យមើលសៀវភៅកំណត់ហេតុកត់ត្រាល្បាត
- ពិនិត្យមើលរបាយការណ៍ល្បាត
- ចូលរួមត្រួតពិនិត្យសកម្មភាពល្បាត
- ចូលរួមវិនិច្ឆ័យករណីនេសាទនៅពេលក្រុមល្បាតរាយការណ៍
- រាយការណ៍ភ្លាមៗទៅអាជ្ញាធរដែលពាក់ព័ន្ធដូចជា ឃុំ ខណ្ឌរដ្ឋបាលជលផល ប៉ូលីស។

ក្រៅពីនេះ ជារៀងរាល់ខែ គណៈកម្មការគ្រប់គ្រងសហគមន៍ស្រះជម្រកត្រីគួររាយការណ៍នូវលទ្ធផលនៃការល្បាតព្រមទាំងពិភាក្សារកដំណោះស្រាយបញ្ហា ដែលជួបប្រទះពេលល្បាតក្នុងកិច្ចប្រជុំប្រចាំខែរបស់ខ្លួនជាមួយឃុំ។

ទន្ទឹមនឹងការអនុវត្តច្បាប់ ក្រុមល្បាត និងប្រធានសហគមន៍ គួរតាមដានអំពីនិន្នាការនៃសកម្មភាពបទល្មើស (កើន ឬថយ)។ ប្រសិនបើ បទល្មើសមានការកើនឡើង ប្រធានសហគមន៍ និងអាជ្ញាធរដែនដី គួរពិភាក្សារកមូលហេតុអំពីកំណើនបទល្មើស និងរៀបចំផែនការសកម្មភាពដើម្បីទប់ស្កាត់ (ឧទាហរណ៍ ផ្សព្វផ្សាយអត្ថប្រយោជន៍ស្រះជម្រកត្រីសហគមន៍ លក្ខន្តិករបស់សហគមន៍ ការអនុវត្តច្បាប់ ស្តីពីជលផល ។ល។)។ ការត្រួតពិនិត្យ វាយតម្លៃ និងរៀបចំផែនការសកម្មភាពនេះគួរធ្វើជាប្រចាំ។

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១៖ វិធានការជំនួយដល់ក្រុមល្បាត

| | | ដំណោះស្រាយ(ករណីជួបជនល្មើស) | ដំណោះស្រាយ(ករណីមិនជួបជនល្មើស) |
|---|---|---|---|
| ប្រភេទបទល្មើសនៅកន្លែងអភិរក្សសហគមន៍(ស្រះជម្រកត្រី និងតំបន់ការពារ) | សកម្មភាពនេសាទដែលខុសទៅនឹងច្បាប់ស្តីពីជលផល | អនុវត្តតាមច្បាប់ស្តីពីជលផល | |
| | ការឃុបឃិតបទល្មើសផ្សេងៗ | អនុវត្តតាមច្បាប់ស្តីពីជលផល | |
| | ការនេសាទដោយប្រើឧបករណ៍នេសាទស្របច្បាប់ស្តីពីជលផលនៅក្នុងកន្លែងអភិរក្ស និងតំបន់ការពារ | សងការខូចខាតក្នុងចំនួនទឹកប្រាក់(កំណត់នៅក្នុងលក្ខន្តិករបស់សហគមន៍រៀងៗខ្លួន) វត្ថុតាងមិនប្រគល់ឱ្យវិញទេ។ | យកឧបករណ៍ចេញ |
| | ការចាក់សំរាមចូល និងចាក់គរសំរាមនៅក្នុង ឬ ក្បែរស្រះជម្រកត្រី | សងការខូចខាត ក្នុងចំនួនទឹកប្រាក់ដែលមានកំណត់នៅក្នុងលក្ខន្តិករបស់សហគមន៍រៀងៗខ្លួន | យកសំរាមចេញ |
| ប្រភេទឧបករណ៍ខុសច្បាប់ | ឧបករណ៍ឆក់ | អនុវត្តតាមច្បាប់ស្តីពីជលផល | យកឧបករណ៍ចេញ |
| | លូស្បៃមុង | អនុវត្តតាមច្បាប់ស្តីពីជលផល | យកឧបករណ៍ចេញ |

| | | | |
|---|---|---|---|
| | | | |
| | ស្បៃមុង ឬសាច់ដៃ | អប់រំណែនាំជនល្មើស អំពីលក្ខន្តិកសហគមន៍ស្រះជម្រកត្រី និងច្បាប់ស្ដីពីជលផល(ចំពោះមាត្រាដែលពាក់ព័ន្ធ) កុំឱ្យប្រព្រឹត្តជាលើកទី២ | យកឧបករណ៍ចេញ |
| | | | |
| | ប្រឹស១០០ (ឧបករណ៍ទំនើប) | អនុវត្តតាមច្បាប់ស្ដីពីជលផល | យកឧបករណ៍ប្រគល់ជូនសមត្ថកិច្ច |
| | លបឬស្បៃមុង កាត់ផ្លូវត្រីចេញ ចូល | អនុវត្តតាមច្បាប់ស្ដីពីជលផល | យកឧបករណ៍ចេញ |

ឧបសម្ព័ន្ធ ២: ទម្រង់កត់ត្រាពីសកម្មភាពចុះល្បាត (អនុវត្តនៅគម្រោងសេហ្វ ស៊ី អេហ្វ អ)

| ថ្ងៃខែ ចុះ ល្បាត | ចំនួនអ្នក ចូលរួម | ភេទ | ចំនួនករណី នៃសាទខុស ច្បាប់ | ចំនួនអ្នក ប្រព្រឹត្ត | ទីតាំង ប្រព្រឹត្ត | ម៉ោង ឃើញ | សកម្មភាព បន្ទាប់ | កត់សំគាល់ ប្រភេទករណី នៃសាទខុស ច្បាប់ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

ឧបសម្ព័ន្ធ ៣៖ គម្រូសេចក្តីសម្រេចការទទួលស្គាល់ក្រុមល្បាត នៅសហគមន៍ស្រះជម្រកត្រី

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ខេត្ត** **កំពង់ធំ**

**ស្រុក** **កំពង់ស្វាយ**

**សាលាឃុំ** **សាន់គ**

លេខ: 3985/2021

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើត និងទទួលស្គាល់ក្រុមល្បាតការពារ និងគ្រប់គ្រងសហគមន៍ស្រះជម្រកត្រី ត្រពាំងអង្គាញ់រៀន**

- យោងព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់។
- យោងអនុក្រឹត្យ លេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាចតួនាទី និង ភារកិច្ចទៅឱ្យក្រុមប្រឹក្សា ឃុំ-សង្កាត់។
- យោងសេចក្តីសំរេចលេខ ០៧០ សសរ.គឃស ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់គណៈកម្មាធិការជាតិ គាំទ្រឃុំ-សង្កាត់។

**សម្រេច**

**ប្រការ១** ៖បង្កើតនិងទទួលស្គាល់ក្រុមល្បាតការពារសហគមន៍ស្រះជម្រកត្រី **ត្រពាំងអង្គាញ់រៀន** នៅក្នុងភូមិក្រសាំង ក ឃុំសាន់គ ស្រុកកំពង់ស្វាយ ដែលមានសមាសភាពចំនួន ០៣ក្រុមដូចខាងក្រោម៖

**ក្រុមទី១** (**ល្បាតពីថ្ងៃចន្ទ ដល់ ថ្ងៃអង្គារ**)

| ល.រ | ឈ្មោះ | តួនាទី |
|---|---|---|
| ១ | លោក សុខ អុល | ប្រធាន |
| ២ | លោក ជួប ម៉ុន | អនុប្រធាន |
| ៣ | លោក ព្រំ សារិទ្ធ | សមាជិក |
| ៤ | លោក ទុយ យាង | សមាជិក |

**ក្រុមទី២** (**ល្បាតពីថ្ងៃពុធដល់ ថ្ងៃព្រហស្បតិ៍**)

| ល.រ | ឈ្មោះ | តួនាទី |
|---|---|---|
| ១ | លោក រៀន រុំ | ប្រធាន |
| ២ | លោក ថាំង ប៉ុញ | អនុប្រធាន |
| ៣ | លោក មុំ គ្រុយ | សមាជិក |
| ៤ | លោក ទូត សំណាង | សមាជិក |

១

**ក្រុមទី៣ (ល្បាតពីសុក្រ ដល់ ថ្ងៃសៅរ៍)**

| ល.រ | ឈ្មោះ | តួនាទី |
|---|---|---|
| ១ | លោក ភាន ភួត | ប្រធាន |
| ២ | លោក បាន គ្រៀន | អនុប្រធាន |
| ៣ | លោក ជួន គីនីន | សមាជិក |
| ៤ | លោក ចាន់ ភៀងឡឹម | សមាជិក |

ចំពោះថ្ងៃអាទិត្យ គឺយាមរួមគ្នា

បញ្ជាក់: ចំពោះវេនល្បាតអាចមានការប្រែប្រួលក្នុងករណីចាំបាច់

- គណៈកម្មការ និងក្រុមល្បាតចូលរួមទប់ស្កាត់បទល្មើសឬផ្តល់ពត៌មានជាបន្ទាន់រាល់បទល្មើសជលផលដែលកើតមានក្នុងសហគមន៍ស្រះជម្រកត្រី និងក្នុងតំបន់ទាំងមូលដល់អាជ្ញាធរដែនដី និងស្ថាប័នជំនាញ ។
- អនុវត្តតាមតួនាទីផ្សេងៗទៀតតាមការណែនាំរបស់សមត្ថកិច្ចរដ្ឋបាលជលផល ។
- ធ្វើរបាយការណ៍រីកចំរើន និង របាយការណ៍ហិរញ្ញវត្ថុ រាយការណ៍ជូន អ្នកពាក់ព័ន្ធនិងសមាជិកសហគមន៍
- ធ្វើទំនាក់ទំនង សហការជាមួយស្ថាប័នជំនាញ អាជ្ញាធរដែនដី និង អ្នកពាក់ព័ន្ធដើម្បីទប់ស្កាត់ និងបង្រ្កាបបទល្មើសជលផល ក្នុងសហគមន៍ស្រះជម្រកត្រី ។
- ប្រជុំគណៈកម្មការសហគមន៍ស្រះជម្រកត្រី ដើម្បីបូកសរុប និង វាយតម្លៃលទ្ធផលការងារដែលបានអនុវត្ត ដោយត្រូវធ្វើឡើងជារៀងរាល់ខែ ត្រីមាស និងប្រចាំឆ្នាំ ។
- ចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំ និងស្ថាប័នជំនាញជលផលតាមការអញ្ជើញ ។
- អប់រំផ្សព្វផ្សាយដល់ប្រជាជន អ្នកពាក់ព័ន្ធ ពីលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសារៈប្រយោជន៍នៃការគ្រប់គ្រងស្រះជម្រកត្រីសហគមន៍ ។

**ប្រការ២** ៖ គ្រប់ស្ថាប័នពាក់ព័ន្ធក្នុងឃុំ ព្រមទាំងអស់លោក លោកស្រី ដែលមានចែងក្នុងប្រការ១និងប្រការ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០២១.

**មេឃុំសាន់គ**

**អ៊ិច ស្រេច**

# ឯកសារយោង


Freed, S., Kura, Y., Sean, V., Mith, S., Cohen, P., Thay, S., . . . Kim, M. (2020). Rice field fisheries: Wild aquatic species diversity, food provision services and contribution to inland fisheries. *Fisheries Research*, 12. doi:10.1016/j.fishres.2020.105615

Joffre, O., Mam, K., Kura, Y., Pich, S., & Nao, T. (2012). *Community Fish Refuges in Cambodia-Lessons Learned.* WorldFish.

Kastoryano, S., & Vollaard, B. (2022, September). Nautical Patrol and Illegal Fishing Practics. *Discussion Paper Series-IZA DP No. 15543-Nautical Patrol and Illegal Fishing Practics*. IZA-Institute of labour Economics.

Kim, M., Mam, K., Sean, V., Try, V., Alan, B., Thay, S., . . . Gregory, R. (2019). *Guidelines for community fish refuge-rice field fisheries system management in Cambodia.* Phnom Penh, Cambodia: Cambodia Fisheries Administration. doi:https://hdl.handle.net/20.500.12348/3631